**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៩ អនក្រ.បក

ក្រសួងអភិវឌ្ឍន៍ជនបទ
ចូល
លេខ: ៧០១៤.....ក.អ.ជ
ថ្ងៃទី ២ ១១ ១៥ ម៉ោង ៤:១០
បញ្ជូន...........................

# អនុក្រឹត្យ

## ស្តីពី

## ការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាព លើកញ្ចប់ផលិតផលថ្នាំជក់

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៥/០០៤ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងការពារសុខភាពសាធារណៈនិងកាត់បន្ថយផលប៉ះពាល់ដល់សុខភាព សេដ្ឋកិច្ចសង្គម និងបរិស្ថានដែលបណ្តាលមកពីផលិតផលថ្នាំជក់។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅជាអាទិ៍៖

- កំណត់វិធានការក្នុងការគ្រប់គ្រងការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពលើ កញ្ចប់ផលិតផលថ្នាំជក់
- អប់រំផ្សព្វផ្សាយអំពីផលវិបាកនិងគ្រោះថ្នាក់នៃការប្រើប្រាស់ផលិតផលថ្នាំជក់ ដើម្បីកាត់បន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់
- បង្ការកុមារនិងយុវជនពីការចាប់ផ្តើមប្រើប្រាស់ផលិតផលថ្នាំជក់។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពលើការអនុវត្តចំពោះការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាព លើកញ្ចប់ផលិតផលថ្នាំជក់គ្រប់ប្រភេទដែលត្រូវបានចែកចាយ លក់ និងប្រើប្រាស់នៅក្នុង ព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ៖

- កញ្ចប់ផលិតផលថ្នាំជក់ សំដៅដល់ប្រអប់ ក្រដាស គ្រឿងរុំពីក្រៅឬវត្ថុវេចខ្ចប់ផលិតផលថ្នាំជក់ ដោយមិនរាប់បញ្ចូលបាវឬវត្ថុសម្រាប់ផ្ទុកផលិតផលថ្នាំជក់របស់កសិករ។
- សារព្រមានសុខភាព សំដៅដល់សារជាភាសាខ្មែរនិងជារូបភាពដែលត្រូវបោះពុម្ពលើកញ្ចប់ ផលិតផលថ្នាំជក់ បង្ហាញពីគ្រោះថ្នាក់នៃការប្រើប្រាស់ថ្នាំជក់ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥ ._**

ការត្រួតពិនិត្យនិងការអនុវត្តអនុក្រឹត្យស្តីពីការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាព លើកញ្ចប់ផលិតផលថ្នាំជក់ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល។

## ជំពូកទី៣
## វិធានការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាព លើកញ្ចប់ផលិតផលថ្នាំជក់

**មាត្រា៦ ._**

ផលិតផលថ្នាំជក់ដែលផលិតក្នុងស្រុកឬនាំចូលសម្រាប់ចែកចាយ លក់ និងប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់។

**មាត្រា៧ ._**

ទំហំនិងទីតាំងនៃរូបភាពសារព្រមានសុខភាពដែលត្រូវបោះពុម្ពលើកញ្ចប់ផលិតផលថ្នាំជក់ត្រូវឆ្លើយតបនឹងលក្ខណៈពិសេសដូចខាងក្រោម៖

- សារព្រមានសុខភាពលើកញ្ចប់ផលិតផលថ្នាំជក់ជារូបភាពត្រូវមានទំហំ៥០% និងសារជាភាសាខ្មែរត្រូវមានទំហំ៥% លើផ្ទៃសំខាន់ខាងមុខនិងផ្ទៃសំខាន់ខាងក្រោយ ឬនៅលើផ្ទៃសំខាន់ទាំងអស់ប្រសិនកញ្ចប់មានផ្ទៃលើសពីពីរ។
- សារព្រមានសុខភាពត្រូវបោះពុម្ពលើផ្ទៃសំខាន់ផ្នែកខាងលើនៃកញ្ចប់ផលិតផលថ្នាំជក់ទាំងសងខាង។
- សារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពត្រូវមានភាពងាយមើល ច្បាស់លាស់ មិនហើរពណ៌ មិនរលុប មិនត្រួតគ្នា។
- សារព្រមានសុខភាពជាភាសាខ្មែរត្រូវបោះពុម្ពជាអក្សរដិតពណ៌សលើផ្ទៃពណ៌ខ្មៅនៅផ្នែកខាងលើជាប់សារព្រមានសុខភាពជារូបភាព។

**មាត្រា៨ .–**

សារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពមិនត្រូវបិទបាំងដោយការវេចខ្ចប់ កំណត់សម្គាល់ ឬស្លាកផ្សេងៗដែលមានគោលបំណងរាំងដល់សារព្រមានសុខភាពដូចមានចែងក្នុងអនុក្រឹត្យនេះ លើកលែងតែការបិទតែមប្រិ៍អាករ។

**មាត្រា៩ .–**

គំរូសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាព ដូចមានចែងក្នុងមាត្រា៦និងមាត្រា៧នៃអនុក្រឹត្យនេះ និងរបៀបនៃការផ្លាស់ប្តូរជារៀងទាត់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

## ជំពូកទី៤
## ទោសប្បញ្ញត្តិ

**មាត្រា១០ .–**

ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់។

**មាត្រា១១ .–**

នីតិវិធីនៃការពិន័យអន្តរការណ៍លើអំពើល្មើសដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាលនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១២ .–**

ផលិតករថ្នាំជក់ក្នុងស្រុកនិងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយ លក់ និងប្រើប្រាស់ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា៨នៃអនុក្រឹត្យនេះត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួន៤ ០០០ ០០០(បួនលាន)រៀល។

ក្នុងករណីដែលទទួលពិន័យអន្តរការណ៍ម្តងរួចមកហើយ នៅតែប្រព្រឹត្តល្មើសទៀត ត្រូវទទួលពិន័យទ្វេដង។

**មាត្រា១៣ .–**

អ្នកចែកចាយនិងអ្នកលក់ដុំផលិតផលថ្នាំជក់គ្រប់ប្រភេទដែលចែកចាយនិងលក់ផលិតផលថ្នាំជក់គ្មានសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាព ឬបិទបាំងដោយការវេចខ្ចប់ កំណត់សម្គាល់ ឬស្លាកផ្សេងៗដែលរាំងដល់គោលបំណងនៃសារព្រមានសុខភាព ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួន២ ០០០ ០០០

(ពីរលាន)រៀល។ ក្នុងករណីទទួលពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែប្រព្រឹត្តល្មើសទៀត ត្រូវទទួលពិន័យទ្វេដង។

**មាត្រា១៤ ._**

អ្នកលក់រាយផលិតផលថ្នាំជក់គ្រប់ប្រភេទដែលចែកចាយនិងលក់ផលិតផលថ្នាំជក់គ្មានសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាព ឬបិទបាំងដោយការវេចខ្ចប់ កំណត់សម្គាល់ ឬស្លាកផ្សេងៗដែលរារាំងដល់គោលបំណងនៃសារព្រមានសុខភាព ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួន១០ ០០០(មួយម៉ឺន)រៀល។ ក្នុងករណីទទួលពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែប្រព្រឹត្តល្មើសទៀត ត្រូវទទួលពិន័យទ្វេដង។

**មាត្រា១៥ ._**

មន្ត្រីមានសមត្ថកិច្ចណាមួយដែលរំលោភបំពានមុខងារ ដូចមានចែងក្នុងមាត្រា៥នៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលនិងទោសដែលមានក្នុងច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា១៦ ._**

ផលិតករក្នុងស្រុកនិងអ្នកនាំចូលសម្រាប់ធ្វើការចែកចាយនិងលក់ផលិតផលថ្នាំជក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តតាមអនុក្រឹត្យនេះ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមានបានរយៈពេល៩(ប្រាំបួន)ខែ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៧ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ៧ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ